# ការជជែកជាមួយឌឺ វល៊ិ អំពីការជួយដល់ជនភៀសខ្លួន



*វិល មកពីរដ្ឋ ផែនស៊ីលវេញ៉ា ស.រ.អា. ។ យើងបានសួរគាត់នូវសំណួរមួយចំនួនអំពីគម្រោងមួយដែលគាត់បានធ្វើដើម្បីជួយដល់អ្នកដទៃ ។*





**សូមធ្វើការណែនាំខ្លួនឯង ។**

ខ្ញុំមានអាយុ ១១ ឆ្នាំ ។ ខ្ញុំចូលចិត្តលេងកីឡាបាល់ទាត់ និង ឡាកូស ដុតនំខូឃីស៍ ហែលទឹក ជិះស្គី និងជិះស្គីស្បែកជើងរអិលមានកង់ ។ ខ្ញុំក៏លេងព្យាណូ និងវីយ៉ូឡុងផងដែរ ។ ពណ៌ដែលខ្ញុំចូលចិត្តគឺពណ៌ខៀវចាស់ ហើយអាហារដែលខ្ញុំចូលចិត្តជាងគេ គឺស៊ុត ( ក្រឡុក ចៀន ស្ងោរ–ខ្ញុំចូលចិត្តទាំងអស់ ! ) ។ នៅពេលខ្ញុំធំឡើង ខ្ញុំចង់ធ្វើជាវេជ្ជបណ្ឌិតដូចជាប៉ារបស់ខ្ញុំដែរ ។

**តើអ្វីបានធ្វើឲ្យប្អូនមានគំនិតដើម្បីជួយគេ ?**

ខ្ញុំបានឮថាក្រុមគ្រួសារជាច្រើនមកពីប្រទេសមួយផ្សេងទៀត កំពុងរត់គេចខ្លួនដើម្បីសុវត្ថិភាពរបស់ពួកគេ ។ ពួកគេមួយចំនួនបានផ្លាស់ប្ដូរទៅតំបន់មួយ ដែលនៅជិតនោះ ។ ភ្លាមនោះខ្ញុំបានគិត « តើខ្ញុំអាចជួយពួកគេបានយ៉ាងដូចម្ដេច ? »

ខ្ញុំបានពោលពាក្យអធិស្ឋានមួយដើម្បីដឹងអំពីរបៀបដែលខ្ញុំអាចជួយបាន ។ បន្ទាប់មកម្ដាយរបស់ខ្ញុំបានទទួលអ៊ីម៉ែលមកពីសមាគមសង្គ្រោះស្ដេក ។ ពួកគេបានស្នើឲ្យមនុស្សបរិច្ចាគវត្ថុនានា ដើម្បីផ្ដល់ជូនដល់ក្រុមគ្រួសារជនភៀសខ្លួន ។ ខ្ញុំដឹងថាការអធិស្ឋានរបស់ខ្ញុំត្រូវបានឆ្លើយតប !



**តើប្អូនជួយដោយរបៀបណា ?**

ខ្ញុំចូលចិត្តដុតនំ ( ជំនាញពិសេសរបស់ខ្ញុំគឺនំខូឃីស៍ ) ដូច្នេះខ្ញុំបានសម្រេចចិត្តលក់នំខូឃីស៍ដើម្បីរកប្រាក់សម្រាប់គ្រួសារទាំងនេះ ។ ខ្ញុំបានធ្វើក្រដាសប្រកាស ហើយជិះស្បែកស្ដីដែលមានកង់របស់ខ្ញុំទៅជុំវិញតំបន់ជិតខាងដើម្បីយកនំទាំងនោះទៅឲ្យពួកគេ ។ ឆ្កែរបស់ខ្ញុំ កូកូ ក៏មកដែរ ។

អ្នកជិតខាងរបស់ខ្ញុំជាច្រើនមានចិត្តរំភើប ក្នុងការទិញនំខូឃីស៍របស់ខ្ញុំ ។ ចំពោះប្រាក់ដែលខ្ញុំរកបាន ខ្ញុំបានទិញឆ្នាំង និងខ្ទះដើម្បីបរិច្ចាគ ។



**តើប្អូនមានអារម្មណ៍យ៉ាងណាដែរ ?**

ខ្ញុំមានអារម្មណ៍ល្អដោយដឹងថាក្រុមគ្រួសារទាំងនេះនឹងអាចធ្វើម្ហូបដោយប្រើឆ្នាំង និងខ្ទះទាំងនេះ ។ ខ្ញុំគ្រាន់តែចង់ស្រមៃថាអាហារដែលធ្វើនៅផ្ទះដោយងាយស្រួលនឹងមានរសជាតិឆ្ងាញ់យ៉ាងណានៅពេលដែលអ្នករស់នៅក្នុងប្រទេសថ្មីមួយ ។



ខ្ញុំបានរៀននៅក្នុងអង្គការបឋមសិក្សាថា « កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ » ( ម៉ូសាយ ២:១៧ ) ។ ខ្ញុំមានអារម្មណ៍ថា ព្រះវរបិតាសួគ៌ស្រឡាញ់ខ្ញុំ និងប្រជាជនដែលផ្លាស់មកក្នុងតំបន់របស់ខ្ញុំ ។

**តើប្អូនមានដំបូន្មានអ្វីខ្លះដល់អ្នកដទៃដែលចង់ជួយដែរទេ ?**

ស្វែងរកវិធីដើម្បីបម្រើនៅក្នុងវួដ ឬស្ដេករបស់អ្នក ។ អ្នកក៏អាចជួយដល់អង្គការផ្ដល់ទីជម្រកនៅក្នុងតំបន់របស់អ្នកបានផងដែរ។ មានវិធីជាច្រើនដើម្បីជួយគ្រប់កន្លែងទាំងអស់ ! ●

